ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងមុខងារសាធារណៈ

លិខិតជូនពរ

សូមគោរពជូន

សម្តេចតិបុលសេនាតន្តី សាយ ឈុំ ប្រធានព្រឹទ្ធសភា នៃព្រះរាជាណាចក្រកម្ពុជា

សម្តេចតិបុលសេនាតន្តី ជាទីគោរពដ៏ខ្ពង់ខ្ពស់!

ក្នុងឱកាសដ៏មហាប្រសើរប្រកបដោយក្តីសោមនស្សរីករាយ នៃពិធីបុណ្យចូលឆ្នាំថ្មីប្រពៃណីជាតិ ឆ្នាំថោះ បញ្ចស័ក ពុទ្ធសករាជ ២៥៦៧ យើងខ្ញុំទាំងអស់គ្នា ជាថ្នាក់ដឹកនាំ និងមន្ត្រីរាជការ នៃក្រសួងមុខងារសាធារណៈ សូមសម្តែងនូវអំណរសាទរប្រកបដោយកតញ្ញូកតវេទិតាធម៌យ៉ាងជ្រាលជ្រៅបំផុត និងសូមគោរពជូនពរ បវរសួស្តី សិរីមង្គល វិបុលសុខដ៏មហាប្រសើរគ្រប់ប្រការជូន **សម្តេចតិបុលសេនាតន្តី** សូមមានសុខភាពល្អបរិបូរណ៌ បញ្ញាញាណភ្លឺថ្លា កាយពលមាំមួន និងជន្មាយុយឺនយូរ ដើម្បីបន្តដឹកនាំស្ថាប័នព្រឹទ្ធសភាឱ្យសម្រេចបាននូវជ័យជម្នះធំៗជាច្រើនថែមទៀត រួមចំណែកយ៉ាងសំខាន់ដល់ការពង្រឹងនីតិរដ្ឋ ដំណើរការលទ្ធិប្រជាធិបតេយ្យ និងការអភិវឌ្ឍប្រទេសឱ្យកាន់តែមានភាពសម្បូរសប្បាយ និងសុភមង្គលជូនប្រជាជាតិខ្មែរ នៅក្រោមដំបូលនៃសុខសន្តិភាពនិង ភាពរុងរឿងជាតិ។

ឆ្លៀតក្នុងឱកាសដ៏ប្រពៃថ្លៃថ្លា នៃពិធីបុណ្យចូលឆ្នាំថ្មីប្រពៃណីជាតិ ឆ្នាំថោះ បញ្ចស័ក ពុទ្ធសករាជ ២៥៦៧ យើងខ្ញុំទាំងអស់គ្នា សូមបួងសួងដល់គុណបុណ្យព្រះរតនត្រ័យ និងវត្ថុស័ក្តិសិទ្ធិទាំងអស់ក្នុងលោក តេជៈបារមីទេវតារក្សាទឹកដីនៃព្រះរាជាណាចក្រកម្ពុជា ព្រមទាំងទេវតាឆ្នាំថ្មី ព្រះនាម **ភិមិរនេឞី** សូមយាងប្រោសប្រទានសព្វសាធុការពរជូន **សម្តេចតិបុលសេនាតន្តី និងលោកជំទាវ ព្រមទាំងបុត្រា បុត្រី ចៅប្រុស ចៅស្រី** សូមមានសុខភាពល្អបរិបូរណ៌ ដើម្បីបន្តចូលរួមចំណែកដឹកនាំ កសាងអភិវឌ្ឍជាតិមាតុភូមិឱ្យកាន់តែសម្បូរសប្បាយនិងសុភមង្គល ជូនប្រជាជាតិខ្មែរនៅក្រោមដំបូលនៃសុខសន្តិភាព និងភាពរុងរឿងជាតិ។

សូម **សម្តេចតិបុលសេនាតន្តី និងលោកជំទាវ ព្រមទាំងបុត្រា បុត្រី ចៅប្រុស ចៅស្រី** សមប្រកបនឹងព្រះពុទ្ធពរដ៏មហាប្រសើរទាំងបួនប្រការគឺអាយុ វណ្ណៈ សុខៈ និងពលៈ កុំបីឃ្លៀងឃ្លាតឡើយ។

សូម **សម្តេចតិបុលសេនាតន្តី ប្រធានព្រឹទ្ធសភា នៃព្រះរាជាណាចក្រកម្ពុជា** មេត្តាទទួលនូវសេចក្តីគោរពដ៏ខ្ពង់ខ្ពស់ពីយើងខ្ញុំទាំងអស់គ្នា។

ថ្ងៃ ២ កើត ខែជេষ្ঠ ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៦
រាជធានីភ្នំពេញ ថ្ងៃទី ១០ ខែ ឧសភា ឆ្នាំ២០២៣
តំណាងថ្នាក់ដឹកនាំនិងមន្ត្រីរាជការនៃក្រសួងមុខងារសាធារណៈ
រដ្ឋមន្ត្រី

ហ៊ុ សុខា

ផ្លូវវត្តអង្គតាមុិញ ភូមិគោកចំបក់ សង្កាត់ចោមចៅ ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
ទូរស័ព្ទ/ទូរសារ : +៨៥៥-២៣-៨៦៦៥០១/+៨៥៥-២៣-៨៦៦៥០៥ | គេហទំព័រ : http://www.mcs.gov.kh